**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ៣៧៦៤ បទ.

ថ្ងៃ ពុធ ១២កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាប់ផ្តើមដំណើរការជាផ្លូវការប្រតិបត្តិការ សេវាទូរសព្ទចល័តជំនាន់ទី៥ (សេវា 5G) នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជម្រាបជូនសាធារណជនទាំងអស់ជ្រាបថា កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការដាក់ឱ្យដំណើរការប្រតិបត្តិការ **សេវាទូរសព្ទចល័តជំនាន់ទី៥ (សេវា 5G)** នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីខែមករា ឆ្នាំ២០២៦ តទៅ។ ក្នុងន័យនេះ **ក.ប.ទ.** បានសហការជាមួយគ្រប់ប្រតិបត្តិករទូរសព្ទចល័តធំៗទាំង ៣ គឺ ក្រុមហ៊ុន Cellcard (CamGSM) ក្រុមហ៊ុន Metfone (Viettel Cambodia) និងក្រុមហ៊ុន Smart (Smart Axiata) ជំរុញការសាងសង់ស្ថានីយអង់តែនទូរគមនាគមន៍ និងបំពាក់ឧបករណ៍ផ្តល់សេវា 5G នៅតាមទីតាំងដូចមានផែនទីលម្អិតក្នុងឧបសម្ព័ន្ធជូនភ្ជាប់។

ស្របពេលនឹងការអបអរសាទរការឆ្លងឆ្នាំចាស់ឈានចូលឆ្នាំថ្មី ឆ្នាំសកលនេះ អ្នកប្រើប្រាស់សេវារបស់ប្រតិបត្តិករទូរសព្ទចល័តទាំង ៣ ខាងលើ នឹងអាចចាប់ផ្តើមប្រើប្រាស់សេវា 5G បាន **ចាប់ពីម៉ោង 00:01 នៃថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ នេះតទៅ** នៅតាមទីតាំងដូចបានជម្រាបជូនខាងលើ ដែលនៅដំណាក់កាលដំបូង គឺនៅរាជធានីភ្នំពេញ និងតំបន់សំខាន់ៗមួយចំនួននៅក្នុងខេត្តសៀមរាប ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តកំពត។ ជាជំហានៗបន្តទៀត វិសាលភាពគ្របដណ្តប់នៃសេវា 5G នឹងពង្រីកឱ្យបានកាន់តែទូលំទូលាយបន្ថែមទៀត និងទៅកាន់គ្រប់បណ្តាខេត្តផ្សេងទៀតនៅទូទាំងប្រទេស។

សេវា 5G នឹងចូលរួមចំណែកយ៉ាងសំខាន់ៗក្នុងការជំរុញបរិវត្តកម្មឌីជីថលក្នុងសេដ្ឋកិច្ចនិងសង្គម ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ តាមរយៈការផ្តល់មកនូវអត្ថប្រយោជន៍ជាច្រើន ដូចជា សេវាអ៊ីនធឺណិតមានល្បឿនលឿនជាងសេវា 4G ការតភ្ជាប់ឧបករណ៍បានច្រើនក្នុងពេលតែមួយ រយៈពេលនៃការឆ្លើយតប (Latency) មានកម្រិតទាប និងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឌីជីថល ជាដើម។ សេវា 5G មិនមែនត្រឹមតែមាន "អ៊ីនធឺណិតល្បឿនលឿន" ប៉ុណ្ណោះទេ ប៉ុន្តែសេវានេះ នឹងក្លាយជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់អនាគតឌីជីថល នវានុវត្តន៍ និងកាលានុវត្តភាពថ្មីៗរបស់ព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាប និងចូលរួមទទួលយកបទពិសោធថ្មីនៃសេវា 5G នេះ។

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Cellcard: ២០០ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

cellcard ROYAL GROUP SINCE 1991

| ល.រ | រាជធានី/ខេត្ត/ក្រុង/ខណ្ឌ/ស្រុក | ចំនួនស្ថានីយ 5G |
|---|---|---|
| **១.** | **រាជធានីភ្នំពេញ** | **១៨៦** |
| ១-១ | ខណ្ឌបឹងកេងកង | ១៧ |
| ១-២ | ខណ្ឌចំការមន | ៣១ |
| ១-៣ | ខណ្ឌច្បារអំពៅ | ២៦ |
| ១-៤ | ខណ្ឌដង្កោ | ២ |
| ១-៥ | ខណ្ឌដូនពេញ | ៤៣ |
| ១-៦ | ខណ្ឌមានជ័យ | ១២ |
| ១-៧ | ខណ្ឌ៧មករា | ១៣ |
| ១-៨ | ខណ្ឌឫស្សីកែវ | ៥ |
| ១-៩ | ខណ្ឌសែនសុខ | ១០ |
| ១-១០ | ខណ្ឌទួលគោក | ២៧ |
| **២.** | **ខេត្តកណ្ដាល** | **១៤** |
| ២-១ | ស្រុកកណ្ដាលស្ទឹង | ២ |
| ២-២ | ក្រុងតាខ្មៅ | ១២ |



# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Smart : ២៨៣ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

| ល.រ | រាជធានី/ខេត្ត/ក្រុង/ខណ្ឌ/ស្រុក | ចំនួនស្ថានីយ 5G |
|---|---|---|
| **១.** | **រាជធានីភ្នំពេញ** | **២៥៨** |
| ១-១ | ខណ្ឌបឹងកេងកង | ៨ |
| ១-២ | ខណ្ឌចំការមន | ១១ |
| ១-៣ | ខណ្ឌច្បារអំពៅ | ១៤ |
| ១-៤ | ខណ្ឌជ្រោយចង្វារ | ២១ |
| ១-៥ | ខណ្ឌដង្កោ | ១០ |
| ១-៦ | ខណ្ឌដូនពេញ | ១១ |
| ១-៧ | ខណ្ឌកំបូល | ៧ |
| ១-៨ | ខណ្ឌមានជ័យ | ៣២ |
| ១-៩ | ខណ្ឌពោធិ៍សែនជ័យ | ៤៧ |
| ១-១០ | ខណ្ឌព្រែកព្នៅ | ៤ |
| ១-១១ | ខណ្ឌ៧មករា | ៦ |
| ១-១២ | ខណ្ឌឫស្សីកែវ | ១៩ |
| ១-១៣ | ខណ្ឌសែនសុខ | ៥០ |
| ១-១៤ | ខណ្ឌទួលគោក | ១៨ |
| **២.** | **ខេត្តកណ្ដាល** | **២៤** |
| ២-១ | ក្រុងតាខ្មៅ | ១៣ |
| ២-២ | ស្រុកអង្គស្នួល | ២ |
| ២-៣ | ស្រុកកណ្ដាលស្ទឹង | ១ |
| ២-៤ | ស្រុកមុខកំពូល | ៥ |
| ២-៥ | ស្រុកពញាឮ | ៣ |
| **៣.** | **ខេត្តតាកែវ** | **១** |
| ៣-១ | ស្រុកបាទី | ១ |



# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

| ល.រ | រាជធានី/ខេត្ត/ក្រុង/ខណ្ឌ/ស្រុក | ចំនួនស្ថានីយ 5G |
|---|---|---|
| **១.** | **រាជធានីភ្នំពេញ** | **១៥៤** |
| ១-១ | ខណ្ឌបឹងកេងកង | ៩ |
| ១-២ | ខណ្ឌចំការមន | ៣០ |
| ១-៣ | ខណ្ឌច្បារអំពៅ | ៧ |
| ១-៤ | ខណ្ឌជ្រោយចង្វារ | ៤ |
| ១-៥ | ខណ្ឌដង្កោ | ២ |
| ១-៦ | ខណ្ឌដូនពេញ | ២៤ |
| ១-៧ | ខណ្ឌមានជ័យ | ១៧ |
| ១-៨ | ខណ្ឌពោធិ៍សែនជ័យ | ៤ |
| ១-៩ | ខណ្ឌ៧មករា | ១២ |
| ១-១០ | ខណ្ឌឫស្សីកែវ | ៥ |
| ១-១១ | ខណ្ឌសែនសុខ | ២១ |
| ១-១២ | ខណ្ឌទួលគោក | ១៩ |
| **២.** | **ខេត្តកណ្ដាល** | **១៤** |
| ២-១ | ក្រុងតាខ្មៅ | ១០ |
| ២-២ | ស្រុកអង្គស្នួល | ១ |
| ២-៣ | ស្រុកកណ្ដាលស្ទឹង | ២ |
| ២-៤ | ស្រុកកៀនស្វាយ | ១ |



# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)







| ៣. | ខេត្តកំពង់ចាម | ៤ |
|---|---|---|
| ៣-១ | ក្រុងកំពង់ចាម | ៤ |

| ៤. | ខេត្តកំពង់ធំ | ១ |
|---|---|---|
| ៤-១ | ក្រុងស្ទឹងសែន | ១ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

metfone




| ៥. | ខេត្តក្រចេះ | ១ |
|---|---|---|
| ៥ -១ | ក្រុងក្រចេះ | ១ |




| ៦. | ខេត្តស្ទឹងត្រែង | ១ |
|---|---|---|
| ៦ -១ | ក្រុងស្ទឹងត្រែង | ១ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)







| ៧. | ខេត្តកំពង់ឆ្នាំង | ១ |
|---|---|---|
| ៧-១ | ក្រុងកំពង់ឆ្នាំង | ១ |

| ៨. | ខេត្តពោធិ៍សាត់ | ១ |
|---|---|---|
| ៨-១ | ក្រុងពោធិ៍សាត់ | ១ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)




| ៩. | ខេត្តស្វាយរៀង | ៩ |
|---|---|---|
| ៩-១ | ក្រុងស្វាយរៀង | ៤ |
| ៩-២ | ក្រុងបាវិត | ៥ |




| ១០. | ខេត្តព្រៃវែង | ៣ |
|---|---|---|
| ១០-១ | ក្រុងព្រៃវែង | ៣ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

metfone




| ១១. | ខេត្តកំពង់ស្ពឺ | ៨ |
|---|---|---|
| ១១-១ | ក្រុងច្បារមន | ៦ |
| ១១-២ | ស្រុកសំរោងទង | ២ |




| ១២. | ខេត្តតាកែវ | ៥ |
|---|---|---|
| ១២-១ | ក្រុងដូនកែវ | ៣ |
| ១២-២ | ស្រុកបាទី | ២ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

metfone





| ១៣. | ខេត្តព្រះសីហនុ | ១ |
|---|---|---|
| ១៣-១ | ក្រុងព្រះសីហនុ | ១ |

| ១៤. | ខេត្តកំពត | ១ |
|---|---|---|
| ១៤-១ | ក្រុងកំពត | ១ |

# តារាងសង្ខេបចំនួនអង់តែន 5G របស់ក្រុមហ៊ុន Metfone : ២២០ ស្ថានីយ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ទីតាំងផ្សេងទៀតកំពុងបន្តសាងសង់)

metfone





| | | |
|---|---|---|
| **១៥.** | **ខេត្តសៀមរាប** | **១៦** |
| ១ ៥ -១ | ក្រុងសៀមរាប | ១៥ |
| ១ ៥ -២ | ស្រុកសូទ្រនិគម | ១ |